# សំណួរដែលតែងសួរអំពីវ៉ាក់សាំងកូវីដ-១៩

## សារគន្លឹះ

- សុវត្ថិភាព និងប្រសិទ្ធភាពរបស់វ៉ាក់សាំង គឺជាឧបករណ៍ដ៏សំខាន់ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងដើម្បីសង្គ្រោះជីវិត ដោយត្រូវអនុវត្តរួមជាមួយនឹងវិធានការណ៍ផ្សេងៗ ដូចជា ពាក់ម៉ាស់ រក្សាគម្លាត និងលាងសម្អាតដៃ។
- ដំណើរការនៃការអនុម័តចំពោះវ៉ាក់សាំងថ្មី បានអនុវត្តតាមស្តង់ដាខ្ពស់ នៃបទប្បញ្ញតិរបស់វ៉ាក់សាំងដូចជាការផលិតវ៉ាក់សាំងនានាកន្លងមកដែរ។
- អាទិភាពសំខាន់គឺត្រូវការពារប្រព័ន្ធសុខាភិបាល និងអ្នកដែលមានហានិភ័យខ្ពស់ទៅនឹងជំងឺធ្ងន់ធ្ងរ។ នេះគឺជាយុទ្ធសាស្ត្រល្អបំផុតក្នុងការកាត់បន្ថយនូវផលប៉ះពាល់ដ៏ធំនៃចំនួនវ៉ាក់សាំងដែលមានសម្រាប់ដំណាក់កាលដំបូង ហើយក៏ដើម្បីចាប់ផ្តើមស្តារការប៉ះពាល់សេដ្ឋកិច្ចសង្គមដោយការរាតត្បាតជាសកលនៃជំងឺនេះ។
- វ៉ាក់សាំងមិនគ្រាន់តែសង្គ្រោះជីវិត និងធ្វើឱ្យប្រព័ន្ធសុខាភិបាលមានលំនឹងប៉ុណ្ណោះទេ ប៉ុន្តែវានឹងជួយស្តារសេដ្ឋកិច្ចឡើងវិញផងដែរ។ គឺជាការសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា ទោះបីជាយើងមានករណីជំងឺកូវីដ-១៩ តិចតួចក្នុងប្រទេសក៏ពិតមែន ប៉ុន្តែរងនូវផលប៉ះពាល់សេដ្ឋកិច្ចសង្គមដោយសារការរីករាលដាលជាសកល។
- សុវត្ថិភាពរបស់អ្នកបម្រើការងារផ្នែកសុខាភិបាល និងក្រុមគោលដៅដែលត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ គឺជាការសំខាន់ណាស់។ វ៉ាក់សាំងនឹងត្រូវផ្តល់ឱ្យដោយគោរពតាមពិធី សារសុវត្ថិភាពយ៉ាងម៉ត់ចត់។



# សុវត្ថិភាពរបស់វ៉ាក់សាំងកូវីដ-១៩

១. តើខ្ញុំគួរធ្វើអ្វីខ្លះដើម្បីការពារខ្លួនពីជំងឺកូវីដ-១៩ ក្នុងអំឡុងពេលរង់ចាំវ៉ាក់សាំងកូវីដ-១៩?

អ្នកគួរបន្តពាក់ម៉ាស់ លាងដៃឱ្យបានញឹកញាប់ និងរក្សាគម្លាតពីអ្នកដទៃយ៉ាងតិច ១,៥ម៉ែត្រ។ ជៀសវាងទៅកន្លែងមនុស្សអ៊ូអរ កន្លែងមានមនុស្សនៅជិតគ្នា និងកន្លែងបិទជិត មិនមានខ្យល់ចេញចូលគ្រប់គ្រាន់ និងជៀសវាងការឱបគ្នា ចាប់ដៃគ្នា កៀកស្មាគ្នា។ ការអនុវត្តទាំងអស់នេះ នឹងជួយអ្នកកាត់បន្ថយនូវឱកាសក្នុងការឆ្លង និងចម្លងទៅអ្នកដទៃ។

បើទោះបីជាអ្នកបានចាក់វ៉ាក់សាំងរួចហើយក៏ដោយ អ្នកគួរបន្តអនុវត្តវិធានការបង្ការនេះ ពីព្រោះយើងមិនទាន់ដឹងថាតើវ៉ាក់សាំងនឹងបញ្ឈប់អ្នកមិនឱ្យចម្លងមេរោគ ទៅអ្នកដទៃបានឬទេ ប្រសិនបើអ្នកបានប៉ះពាល់មេរោគកូវីដ-១៩។

២. តើវ៉ាក់សាំងកូវីដ-១៩ មានសុវត្ថិភាពដែរ ឬទេ?

គ្រប់ដំណាក់កាលទាំងអស់នៃការផលិតវ៉ាក់សាំងកូវីដ-១៩ ត្រូវបានអនុវត្តដូចទៅនឹងការផលិតវ៉ាក់សាំងដទៃផងដែរ។ វ៉ាក់សាំងគឺត្រូវការឆ្លងកាត់ជាច្រើនក្នុងការផលិត និងធ្វើតេស្តសាកល្បង ហើយជាទូទៅគឺមានការធ្វើតេស្តគ្លីនិកចំនួន៣លើក។ គ្រប់ដំណាក់កាល ទាំងអស់គឺវាយតម្លៃទៅលើសុវត្ថិភាព។ ហើយការធ្វើតេស្តសាកល្បងលើកទី៣ គឺតែងតែធ្វើទៅលើមនុស្សជាច្រើននាក់ ហើយធម្មតាគឺមួយម៉ឺននាក់។ ប្រទេសកម្ពុជាមានអាជ្ញាធរបញ្ញាតិ របស់ខ្លួនដែលស្ថិតនៅក្រោម ក្រសួងសុខាភិបាល។ ក្រសួងសុខាភិបាល នឹងចេញសេចក្ដីប្រកាសអនុញ្ញាតឱ្យប្រើប្រាស់វ៉ាក់សាំង ក្នុងគ្រាអាសន្ន បន្ទាប់ពីបានពិនិត្យលើទិន្នន័យដែលមានពីអាជ្ញាធរបទប្បញ្ញាតិ នៃប្រទេសផ្សេង ទៅលើសុវត្ថិភាព និងប្រសិទ្ធភាពរបស់វ៉ាក់សាំងនោះ ឬបន្ទាប់ពីវ៉ាក់សាំងនោះបានដាក់បញ្ចូលទៅក្នុងបញ្ជីប្រើប្រាស់ ក្នុងគ្រាអាសន្នរបស់ អង្គការសុខភាពពិភពលោក (Emmergency Use List EUL)។

នៅពេលដែលវ៉ាក់សាំងដាក់ឱ្យប្រើប្រាស់ នោះនឹងមានការតាមដាន ដើម្បីឱ្យប្រាកដថា មានសុវត្ថិភាពដល់អ្នកចាក់វ៉ាក់សាំង។

៣. តើខ្ញុំអាចកើតជំងឺកូវីដ-១៩ ដោយសារការចាក់វ៉ាក់សាំង ដែរ ឬ ទេ?

មិនមានវ៉ាក់សាំងណាមួយ ក្នុងពេលបច្ចុប្បន្ននេះ មានផ្ទុកវីរុសសកម្មដែលបណ្ដាលឱ្យកើតជំងឺកូវីដ-១៩ នោះទេ។ មានន័យថា វ៉ាក់សាំងកូវីដ-១៩ មិនអាចធ្វើឱ្យអ្នកកើតជំងឺកូវីដ-១៩នោះឡើយ។

ប៉ុន្តែដូចវ៉ាក់សាំងផ្សេងៗដទៃទៀតដែរ ផលរំខានខ្លះៗអាចនឹងកើតមានឡើង។ ប៉ុន្តែជាធម្មតា គឺមានផលរំខានតិចតួច ដូចជា: ឈឺ ឬ មានហើម នៅកន្លែងចាក់ ឬ ក្ដៅខ្លួនតិចតួច ហើយវានឹងបាត់ទៅវិញក្នុងអំឡុងពេល ២-៣ ថ្ងៃ។ ផលរំខានធ្ងន់ធ្ងរអាចកើតមានឡើងដែរ តែកម្រ។

## ៤. ប្រសិនបើខ្ញុំមានជំងឺប្រចាំកាយ តើការចាក់វ៉ាក់សាំងកូវីដ-១៩ មានសុវត្ថិភាពដែរ ឬទេ?

វ៉ាក់សាំងកូវីដ-១៩ គឺចាំបាច់ណាស់សម្រាប់អ្នកមានជំងឺប្រចាំកាយ ដោយសារពួកគាត់មានហានិភ័យខ្ពស់ក្នុងការឆ្លងជំងឺកូវីដ-១៩។

ប្រសិនបើអ្នកមានជំងឺប្រចាំកាយ សូមពិគ្រោះយោបល់ជាមួយគ្រូពេទ្យជាមុនសិន ថាតើអ្នកអាចចាក់វ៉ាក់សាំងបាន ឬទេ។

ក្នុងករណីកម្រ វ៉ាក់សាំងអាចមានប្រតិកម្មអាលែកហ្ស៊ីកើតឡើង។ ប្រសិនបើអ្នកធ្លាប់មានប្រតិកម្មអាលែកហ្ស៊ី ទៅនឹងវ៉ាក់សាំងណាមួយ ឬ ឱសថណាមួយ ឬ ផលិតផលឱសថ ឬ អាហារ... សូមផ្តល់ព័ត៌មាន និងពិគ្រោះយោបល់ជាមួយគ្រូពេទ្យជាមុនសិន។

## ៥. តើខ្ញុំអាចត្រលប់ទៅមាន ជីវិតដូចធម្មតាវិញទេ បន្ទាប់ពីបានទទួលវ៉ាក់សាំងរួច?

ដរាបណាជំងឺកូវីដ-១៩ នៅតែជាជំងឺឆ្លងសកល អ្នកគួរបន្តអនុវត្តវិធានការបង្ការ ដូចជា ពាក់ម៉ាស់ លាងដៃឱ្យបានញឹកញាប់ និងរក្សាគម្លាត១,៥ម៉ែត្រពីគ្នា។ ជៀសវាងកន្លែងមាន មនុស្សច្រើន កន្លែងបិទជិតមិនមានខ្យល់អាកាសចេញចូល គ្រប់គ្រាន់។ ការអនុវត្តន៍ទាំងអស់នេះ នឹងជួយកាត់បន្ថយឱកាសនៃការឆ្លង និងចម្លងមេរោគទៅអ្នកដទៃ។

ជំងឺកូវីដ-១៩ បានផ្លាស់ប្តូរអ្វីៗជាច្រើន រួមទាំង ការរស់នៅបែបគន្លងថ្មី។ ដរាបណាការឆ្លងរាលដាលនៅតែបន្ត យើងត្រូវទទួលស្គាល់ និងអនុវត្ត "គន្លងថ្មី" ទោះបីបានចាក់វ៉ាក់សាំងហើយក៏ដោយ។

## ៦. បើខ្ញុំមិនចង់ចាក់វ៉ាក់សាំង តើបានឬទេ?

មិនមានអ្នកណាម្នាក់អាចបង្ខំអ្នកឱ្យចាក់វ៉ាក់សាំងនោះទេ។ គឺជាការស្ម័គ្ររបស់មនុស្សម្នាក់ៗ។

មិនថាអ្នកសម្រេចចិត្តបែបណា សូមចាំថា វ៉ាក់សាំងគឺជាឧបករណ៍ដ៏សំខាន់ រួមជាមួយនឹងវិធានការបង្ការផ្សេងទៀត ក្នុងការការពារខ្លួនអ្នក គ្រួសាររបស់អ្នក និងសហគមន៍របស់យើងពីជំងឺកូវីដ-១៩ និង ជួយសង្គ្រោះជីវិត។

## ៧. ហាក់ដូចជាមានវ៉ាក់សាំងច្រើនប្រភេទមកប្រទេសកម្ពុជា តើខ្ញុំអាចជ្រើសរើសវ៉ាក់សាំងដែល ខ្ញុំចង់ចាក់បានដែរ ឬទេ?

អ្នកត្រូវអនុវត្តតាមការណែនាំ របស់អ្នកផ្តល់សេវា។ ប្រភេទវ៉ាក់សាំងដែលចាក់ឱ្យអ្នក គឺអាស្រ័យទៅលើវ៉ាក់សាំងដែលមាននាពេលនោះ និងកត្តាផ្សេងៗទៀត។ គ្រប់វ៉ាក់សាំងដែលយកមកចាក់ទាំងអស់ សុទ្ធតែឆ្លងកាត់ស្តង់ដារសុវត្ថិភាពតឹងរឹង។

យោងតាមព័ត៌មានដែលយើងបានទទួលពេលនេះ គ្រប់វ៉ាក់សាំងទាំងអស់ គឺត្រូវការចាក់ពីរដូស។ អ្នកនឹងទទួលបានវ៉ាក់សាំងក្នុងក្រុមហ៊ុនតែមួយ សម្រាប់ទាំងពីរដូស។

## ៨. តើខ្ញុំត្រូវធ្វើអ្វី ប្រសិនបើខ្ញុំមិនស្រួលខ្លួនក្រោយពីបានចាក់វ៉ាក់សាំងរួច?

គឺជាការធម្មតាទេ ដែលមានផលរំខានខ្លះបន្ទាប់ពីចាក់វ៉ាក់សាំងរួច រួមមានក្រហម

ហើម ឬ ឈឺនៅកន្លែងចាក់។ ផលរំខានផ្សេងទៀតមានដូចជា ក្ដៅខ្លួន ឈឺក្បាល និងចុកដៃជើង ក្នុងអំឡុងប៉ុន្មានថ្ងៃក្រោយចាក់វ៉ាក់សាំង។ ប្រសិនបើអ្នកមានការព្រួយបារម្ភណ៍ សូមទាក់ទងទៅបុគ្គលិកសុខាភិបាល។

ជាការសំខាន់ណាស់ ដែលអ្នកត្រូវប្រាប់ទៅបុគ្គលិកសុខាភិបាលមុនពេលចាក់វ៉ាក់សាំង អំពីស្ថានភាពសុខភាពរបស់អ្នក ឬមានអាលែកហ្ស៊ីទៅនឹងអ្វីមួយនោះ។

មនុស្សគ្រប់រូប ដែលបានចាក់វ៉ាក់សាំងរួចត្រូវនៅក្នុងមូលដ្ឋានសុខាភិបាល រយៈពេល ៣០នាទី ដើម្បីតាមដានពីផលរំខាននានា។ ផលរំខានធ្ងន់ធ្ងរដោយសារវ៉ាក់សាំង ភាគច្រើនគឺកើតឡើងក្នុងអំឡុងពេលនេះ តែវាកម្រនឹងកើតមាន។ មន្ត្រីសុខាភិបាលបានទទួលការ បណ្ដុះបណ្ដាល ពីរបៀបគ្រប់គ្រងស្ថានភាពដែលកម្រកើតឡើងនេះ។

វ៉ាក់សាំងឆ្លងកាត់ នូវការធ្វើតេស្តគ្លីនិកយ៉ាងម៉ត់ចត់ ហើយត្រូវបានអនុម័តឱ្យប្រើប្រាស់ជាមួយនឹងប្រជាជនកាន់តែទូលំទូលាយ បន្ទាប់ពីបានធ្វើតេស្តយ៉ាងម៉ត់ចត់ទៅលើសុវត្ថិភាព និងប្រសិទ្ធភាពរបស់វា ហើយផលប្រយោជន៍មានច្រើនលើសលុបជាងហានិភ័យ។

ផលរំខានធ្ងន់ធ្ងរដោយសារវ៉ាក់សាំង គឺកម្រមានណាស់។ ដើម្បីឱ្យប្រាកដថាយើងក្ដាប់បាននូវករណីកម្រនេះ រួមទាំងផលរំខានដែលអាចកើតមានឡើងក្នុងអំឡុងពេលធ្វើតេស្ត សាកល្បង រាជរដ្ឋាភិបាលមានប្រព័ន្ធតាមដាន សម្រាប់ព្រឹត្តិការណ៍ដែលអាចកើតមានឡើង ទៅលើអ្នកដែលបានចាក់វ៉ាក់សាំងរួច។

### ៩. ខ្ញុំលឺ/ឃើញព័ត៌មានថាអ្នកដែលបានចាក់វ៉ាក់សាំងហើយ ខ្លះនៅតែមានកើតជំងឺកូវីដ-១៩ ឬមានស្លាប់ដោយសារវ៉ាក់សាំងទៀត ហេតុអ្វីខ្ញុំត្រូវប្រថុយចាក់នោះ?

យើងយល់អំពីការព្រួយបារម្ភណ៍ អំពីសុវត្ថិភាពរបស់វ៉ាក់សាំង និងផលរំខាន។ នេះជាការ សមហេតុសមផលហើយ ដែលអ្នកចង់ដឹងព័ត៌មាន ដើម្បីធ្វើការសម្រេចចិត្តរបស់ខ្លួនអ្នក និង គ្រួសាររបស់អ្នក។

វ៉ាក់សាំងបានឆ្លងកាត់ការធ្វើតេស្តសាកល្បងគ្លីនិក ហើយវាទទួលបានការអនុម័តឱ្យប្រើជាមួយនឹងប្រជាជនជាច្រើន បន្ទាប់ពីបានធ្វើតេស្តយ៉ាងម៉ត់ចត់ អំពីសុវត្ថិភាព និងប្រសិទ្ធភាព ហើយលទ្ធផលបង្ហាញថា វាមានផលប្រយោជន៍ ច្រើនជាងហានិភ័យ។

វ៉ាក់សាំងនឹងជួយអ្នក និងអ្នកដទៃ មិនឱ្យឈឺ ដែលជាឧបករណ៍ដ៏សំខាន់ក្នុងការពង្រឹងការទប់ស្កាត់ជំងឺកូវីដ-១៩។

### ១០. ខ្ញុំមានជំងឺប្រចាំកាយទៅហើយ ខ្ញុំមិនគួរចាក់វ៉ាក់សាំងទេ ព្រោះវាអាចបណ្ដាលឱ្យស្លាប់?

សូមពិភាក្សាជាមួយនឹងគ្រូពេទ្យ អំពីការព្រួយបារម្ភណ៍របស់អ្នក។ ពួកគាត់អាចផ្ដល់យោបល់ ថាតើអ្នកគួរចាក់វ៉ាក់សាំង ឬទេ។

# ប្រសិទ្ធភាពរបស់វ៉ាក់សាំង

១១. តើវ៉ាក់សាំងមានប្រសិទ្ធភាពដូចម្តេច?

វ៉ាក់សាំង ធ្វើឱ្យប្រព័ន្ធការពាររាងកាយស្គាល់ និងទប់ស្កាត់មេរោគដោយសុវត្ថិភាព។ វ៉ាក់សាំងមានប្រវត្តិជោគជ័យយូរអង្វែងមកហើយ គឺគេបានប្រើ ដំបូងតាំងពី២២៥ឆ្នាំមកម្ល៉េះ។ តាមរយៈប្រវត្តិសាស្ត្រ មនុស្សបានបង្កើតវ៉ាក់សាំងដោយជោគជ័យ សម្រាប់ប្រឆាំងនឹងជំងឺដែលអាចបណ្តាលឱ្យស្លាប់ជាច្រើន រួមទាំងជំងឺរលាកស្រោមខួរ តេតាណុស កញ្ជ្រឹល គ្រុនស្វិតដៃជើង ហើយឥឡូវនេះគឺជំងឺកូវីដ-១៩។

វ៉ាក់សាំង គឺជាឧបករណ៍ថ្មីដ៏សំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។

១២. តើវ៉ាក់សាំងមានប្រភេទខុសគ្នាអ្វីខ្លះ ?

វ៉ាក់សាំងកូវីដ-១៩ មួយចំនួន បាននឹងកំពុងផលិត ឬបានផលិតហើយរួមមាន៖

- វ៉ាក់សាំងដែលបង្កើតឡើងពីវីរុសដែលគេធ្វើឲ្យវាអកម្ម ឬ ចុះខ្សោយ ដោយគេប្រើទម្រង់ វីរុស ដែលអកម្ម ឬត្រូវគេធ្វើឱ្យខ្សោយ ដូច្នោះវានឹងមិនអាចបណ្តាលឱ្យកើតជំងឺ ប៉ុន្តែវាអាចបង្កើតប្រព័ន្ធភាពស៊ាំរបស់ខ្លួនមនុស្សសម្រាប់ប្រឆាំងនឹងវីរុស។
- វ៉ាក់សាំងដែលបង្កើតឡើងពីប្រូតេអ៊ីន ប្រើបំណែកប្រូតេអ៊ីនវីរុសដែលមិនមានគ្រោះថ្នាក់ ឬសំបកប្រូតេអ៊ីនដែលជាផ្នែកតូចនៃវីរុស ជំងឺកូវីដ-១៩ សម្រាប់បង្កើតប្រព័ន្ធភាពស៊ាំនឹងវីរុសកូវីដ-១៩។
- វ៉ាក់សាំងវិចទ័រមេរោគ ប្រើមេរោគដែលបានបង្កាត់ពូជរួច ដូច្នេះវានឹងយិងយិង មិនអាចបណ្តាលឱ្យឈឺ ប៉ុន្តែវាផលិតប្រូតេអ៊ីនមេរោគកូរូណាដើម្បីបង្កើតភាពស៊ាំដោយសុវត្ថិភាព។

វ៉ាក់សាំងដែលផ្សំពី RNA ឬ DNA វីរុស គឺជាបច្ចេកវិជ្ជាចុងក្រោយ ដែលប្រើហ្សែន RNA ឬ DNA វីរុសទៅបង្កើតប្រូតេអ៊ីនដែលបង្កើតភាពស៊ាំរបស់មនុស្ស ដោយខ្លួនឯងប្រកបដោយសុវត្ថិភាព។

វ៉ាក់សាំងខុសៗគ្នា លក្ខណៈនៃវ៉ាក់សាំងដោយឡែកពីគ្នា រួមទាំងភាពខ្លាំងនៃការបង្កើតប្រព័ន្ធភាពស៊ាំ ចំនួនដូសដែលផលិតសុវត្ថិភាព ប្រព័ន្ធត្រជាក់ និងពេលវេលានៃការផលិត។

១៣. តើត្រូវចាក់វ៉ាក់សាំងប៉ុន្មានដូសត៍ និងចន្លោះពេលប៉ុន្មាន?

តាមរយៈព័ត៌មានដែលមានក្នុងពេលនេះ គ្រប់វ៉ាក់សាំងទាំងអស់ គឺត្រូវចាក់ចំនួនពីរដូស ហើយដូសត៍ទីពីរ គឺចាក់ចន្លោះ ៣ - ៤ សប្តាហ៍ ក្រោយចាក់ដូសត៍ទីមួយ។

ជាការសំខាន់ខ្លាំងណាស់ ដែលអ្នកត្រូវទទួលដូសត៍ទីពីរ បើមិនដូច្នោះទេ វ៉ាក់សាំងមិនមានប្រសិទ្ធភាពល្អទេ។ សូមធ្វើតាមការណែនាំរបស់អ្នកផ្តល់សេវាដល់អ្នក។ អ្នកត្រូវទទួលដូសត៍ទីពីរ ទោះបីមានផលរំខានបន្ទាប់ពីទទួលដូសត៍ទីមួយ ហើយក៏ដោយលើកលែង តែគ្រូពេទ្យណែនាំមិនឱ្យទទួលដូសត៍ទីពីរ។ អ្នកនឹងទទួលវ៉ាក់សាំងពីក្រុមហ៊ុនតែមួយ ទាំងពីរដូសត៍។

១៤. ប្រសិនបើខ្ញុំធ្លាប់កើត ហើយជាសះស្បើយពី ជំងឺកូវីដ-១៩ តើខ្ញុំគួរចាក់វ៉ាក់សាំងប្រឆាំង ជំងឺ កូវីដ-១៩ ដែរឬទេ?

ត្រូវហើយអ្នកត្រូវតែទទួល។ វ៉ាក់សាំងកូវីដ-១៩ គួរផ្ដល់ឱ្យអ្នកទោះបីជាអ្នកធ្លាប់កើតជំងឺកូវីដ-១៩ ហើយក៏ដោយ។ ការបង្ការដែលបានមកពីវ៉ាក់សាំង គឺផ្ដល់ការការពារដែលមានប្រសិទ្ធភាពជាង។

ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ អ្នកដែលកំពុងតែមានជំងឺកូវីដ-១៩ គួរពន្យាពេលក្នុងការចាក់វ៉ាក់សាំង រហូតដល់បានជាពីជំងឺ និងបានរួចផុតពីគោលការណ៍នៃការធ្វើចត្តាឡីស័ក។

១៥. ប្រសិនបើខ្ញុំបានចាក់វ៉ាក់សាំងកូវីដ-១៩ តើអាចនឹងមានលទ្ធផលតេស្តវិជ្ជមាន ជំងឺកូវីដ-១៩ ខុសដែរ ឬទេ (PCR វិជ្ជមាន ឬតេស្តអង់ទីគ័រមន្ទីរពិសោធន៍)?

ការទទួលបានវ៉ាក់សាំងកូវីដ-១៩ នឹងមិនបណ្ដាលឱ្យមានលទ្ធផលតេស្ត PCR វិជ្ជមាន ឬ តេស្តអង់ទីគ័រមន្ទីរពិសោធន៍ នោះទេ ដោយសារការធ្វើតេស្ត PCR នេះ គឺពិនិត្យរកជំងឺដែលសកម្ម មិនមែនតេស្តរកមើលភាពស៊ាំរបស់បុគ្គលឡើយ។

ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ អ្នកគួរចាំថា ការធ្វើតេស្តអង់ទីគ័រ (ឬតេស្តសេរ៉ូឡូជីស) អាចនឹងវិជ្ជមាន ចំពោះមនុស្សដែលបានចាក់វ៉ាក់សាំងរួច ដោយសារតែនោះជាការធ្វើតេស្តជាក់លាក់ ក្នុងការរកភាពស៊ាំជំងឺកូវីដ-១៩ របស់បុគ្គល។

បច្ចុប្បន្ននេះប្រទេសកម្ពុជា គឺមានតែតេស្ត PCR ប៉ុណ្ណោះដែលត្រូវបានប្រើសម្រាប់ធ្វើតេស្ត ជំងឺកូវីដ-១៩ ហើយតេស្តមើលអង់ទីគ័រ និងប្រព័ន្ធការពាររាងកាយ គឺមិនត្រូវបានប្រើជា ប្រចាំនោះទេ។

១៦. បន្ទាប់ពីខ្ញុំបានចាក់វ៉ាក់សាំងរួច តើភាពស៊ាំនោះនឹងមាន រយៈពេលប៉ុន្មាន?

ប្រព័ន្ធភាពស៊ាំ មានរយៈពេលប៉ុន្មានខែបន្ទាប់ពីចាក់វ៉ាក់សាំង ប៉ុន្តែបានយូរប៉ុន្មាននោះ គឺនៅមិនទាន់ដឹងនៅឡើយទេ។ ហេតុដូច្នេះហើយ ការអនុវត្តនូវការបង្ការរបស់ក្រសួងសុខាភិបាល ដូចជា ពាក់ម៉ាស់ លាងដៃឱ្យបានញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គល និងគម្លាតសុវត្ថិភាពសង្គម នៅតែចាំបាច់ក្នុងរយៈពេលនេះ។ អនុវត្តនូវជំហានទាំងនេះដើម្បី ការពារខ្លួនយើង និងមនុស្សជាទីស្រលាញ់ ជាការសំខាន់ណាស់ក្នុងដំណាក់កាលបច្ចុប្បន្ន។

១៧. តើចាំបាច់ត្រូវចាក់វ៉ាក់សាំងធ្វើអ្វី បើយើងបានអនុវត្តវិធានការសុខាភិបាលដូចជាពាក់ម៉ាស់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គល និងគម្លាតសុវត្ថិភាពសង្គម ដែលអាចបង្ការការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ហើយនោះ?

ខណៈពេលដែលសុវត្ថិភាព និងប្រសិទ្ធភាពរបស់វ៉ាក់សាំង ជាឧបករណ៍ដ៏សំខាន់ក្នុងការការពារមនុស្សពីការឆ្លងជំងឺកូវីដ-១៩ មិនមានវិធានការតែមួយ ឬវ៉ាក់សាំងតែមួយមុខគត់ អាចការពារបានទាំងស្រុងនោះទេ។ ការប្រើនូវគ្រប់វិធានការបង្ការទាំងអស់ គឺផ្ដល់នូវការ បង្ការដ៏ល្អបំផុតសម្រាប់អ្នក គ្រួសាររបស់អ្នក និងសហគមន៍របស់អ្នក។

# អ្នកណាខ្លះនឹងបានចាក់វ៉ាក់សាំង

១៨. តើអ្នកណាខ្លះត្រូវបានចាត់ជាអាទិភាពចម្បងក្នុងការចាក់វ៉ាក់សាំង?

យោងតាមអនុសាស្រ្តរបស់ អង្គការសុខភាពពិភពលោក ដោយបរិមាណនៃវ៉ាក់សាំងកូវីដ-១៩ មានកំណត់ និងតាមស្ថានភាពរបស់ប្រទេសកម្ពុជា រាជរដ្ឋាភិបាលបានសម្រេចឱ្យអាទិភាព ទៅលើបុគ្គលិកសុខាភិបាល យោធា និងនរគបាល ជួរមុខ និងមន្ត្រីរដ្ឋាភិបាលជួរ មុខ។

ដោយការចាក់វ៉ាក់សាំង ដល់ក្រុមអាទិភាពក្នុងដំណាក់កាលទីមួយ យើងអាចការពារប្រព័ន្ធ សុខាភិបាល និងកាត់បន្ថយការឈឺធ្ងន់ធ្ងរ ស្លាប់ និងការអាក់ខានសង្គម។

នៅក្នុងផែនការជាតិ ស្ដីអំពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក៏បានដាក់បញ្ចូលក្រុមងាយរងគ្រោះមួយចំនួនទៀត ដូចជា មនុស្សចាស់មនុស្សពេញវ័យ ដែលមានជំងឺប្រចាំកាយ សម្រាប់ការចាក់វ៉ាក់សាំងក្នុងឆ្នាំ ២០២១ នេះផងដែរ។

១៩. តើវ៉ាក់សាំងនឹងចាក់ឱ្យតែក្រុមដែលមានហានិភ័យខ្ពស់មែនទេ?

ដោយសារលទ្ធកម្មវ៉ាក់សាំងមានកំរិត ក្រុមងាយរងគ្រោះ គួរត្រូវចាក់មុនគេ។ អង្គការសុខភាពពិភពលោកបានណែនាំ អំពីក្រុមអាទិភាពនោះ ដោយរួមមាន បុគ្គលិកសុខាភិបាល ដើម្បីរក្សា ដំណើរការនៃប្រព័ន្ធសុខាភិបាល។ ក្រុមងាយរងគ្រោះមួយចំនួនទៀតរួមមាន មនុស្សចាស់ អ្នកដែលមានជំងឺប្រចាំកាយ ដែលមានហានិភ័យនៃការឈឺធ្ងន់បន្ទាប់ពីឆ្លងជំងឺកូវីដ-១៩ និងអ្នកដែលមានហានិភ័យក្នុងការប៉ះពាល់ជាមួយមេរោគ។

ប្រសិនបើអ្នកមិនប្រាកដថា អ្នកស្ថិតក្នុងក្រុមមានហានិភ័យខ្ពស់ ឬក្រុមអាទិភាព សូមសួរទៅបុគ្គលិកសុខាភិបាល។

២០. តើស្ត្រីមានផ្ទៃពោះនឹងបានចាក់វ៉ាក់សាំងកូវីដ-១៩ នេះដែរឬទេ? ឬតើគេគួរ បានចាក់ដែរ ឬទេ?

ដោយសារបច្ចុប្បន្ននេះ មិនមានទិន្នន័យគ្រប់គ្រាន់អំពីសុវត្ថិភាព និងប្រសិទ្ធភាព របស់វ៉ាក់សាំងកូវីដ-១៩ ចំពោះស្ត្រីមានផ្ទៃពោះពួកគេមិនបានណែនាំ ឬ ចាត់ជាក្រុមអាទិភាពក្នុងការបានចាក់វ៉ាក់សាំងនេះទេ នៅក្នុងពេលនេះ។

២១. តើស្ត្រីបំបៅដោះកូនបានចាក់វ៉ាក់សាំងដែរ ឬ ទេ?

ពិតជាបាន។ អង្គការសុខភាពពិភពលោកណែនាំឱ្យចាក់វ៉ាក់សាំងប្រឆាំងកូវីដ-១៩ ដល់ ស្ត្រីដែលបំបៅដោះកូនដែលជាបុគ្គលិកសុខាភិបាល ឬ ថិតក្នុងក្រុមអាទិភាពណាមួយ នៃ ការបានចាក់វ៉ាក់សាំងកូវីដ-១៩។

ការបំបៅដោះកូន បានផ្តល់នូវអត្ថប្រយោជន៍សុខភាពជាច្រើនដល់ស្ត្រី និងកូនរបស់ខ្លួន។ អង្គការសុខភាពពិភពលោក មិនបានណែនាំឱ្យបញ្ឈប់បំបៅដោះកូនបន្ទាប់ពីម្ដាយបាន ចាក់វ៉ាក់សាំងរួចនោះទេ។

### ២២. ហេតុអ្វីបានជាកុមារអាយុក្រោម១៦ឆ្នាំ មិនត្រូវបានចាក់វ៉ាក់សាំងឆាប់ជាងនេះ?

យើងមិនទាន់មានទិន្នន័យ អំពីការចាក់វ៉ាក់សាំងដល់កុមារអាយុក្រោម១៦ឆ្នាំ នៅឡើយទេ ហេតុដូច្នេះហើយយើងមិនទាន់ច្បាស់អំពីសុវត្ថិភាព និងប្រសិទ្ធភាពរបស់វ៉ាក់សាំងនេះចំពោះពួកគេនោះទេ។

សេចក្ដីណែនាំនឹងធ្វើបច្ចុប្បន្នភាព នៅពេលដែលមាន ភ័ស្ដុតាងអំពីប្រសិទ្ធភាព និងសុវត្ថិភាពរបស់វ៉ាក់សាំងកូវីដ-១៩ សម្រាប់កុមារ ក្រោមអាយុ១៦ឆ្នាំ។

វ៉ាក់សាំងខ្លះ ត្រូវបានណែនាំឱ្យចាក់សម្រាប់មនុស្សពេញវ័យដែលមានអាយុពី ១៨ឆ្នាំឡើងទៅ។ ប្រសិនបើអ្នក ឬ សមាជិកគ្រួសារអ្នកអាយុ ១៦ ឬ ១៧ឆ្នាំ សូមពិភាក្សាជាមួយ អ្នកផ្ដល់សេវា មុននឹងចាក់វ៉ាក់សាំង។

### ២៣. ខ្ញុំនៅក្មេង ហើយសុខភាពល្អ ម្យ៉ាងក៏មិនមានការឆ្លងខ្លាំងក្នុងប្រទេសកម្ពុជា ហេតុអ្វីខ្ញុំត្រូវប្រញាប់ចាក់វ៉ាក់សាំងកូវីដ-១៩ ពេលនេះធ្វើអ្វី?

វ៉ាក់សាំង គឺសំខាន់ខ្លាំងណាស់សម្រាប់គ្រប់គ្នា។ ដោយយោងតាមលទ្ធកម្មរបស់វ៉ាក់សាំងមានកំរិត ការចាក់វ៉ាក់សាំង នឹងធ្វើតាមដំណាក់កាល ដោយចាប់ផ្ដើមពីក្រុមអាទិភាពមុន រួមមាន បុគ្គលិកសុខាភិបាល និងមន្ត្រីរាជការជួរមុខ។

ប្រសិនបើអ្នកមិនស្ថិតក្នុងក្រុមអាទិភាពនោះទេ អ្នកអាចរង់ចាំចាក់ពេលក្រោយ។ ក្រសួងសុខាភិបាលនឹងផ្ដល់ការណែនាំ ពីពេលវេលាដែលអ្នកត្រូវចាក់។

វ៉ាក់សាំងត្រូវបានបញ្ជាក់ពីប្រសិទ្ធភាព និងសង្គ្រោះជីវិត។ ដោយការចាក់វ៉ាក់សាំងដល់ក្រុមអាទិភាពក្នុងដំណាក់កាលដំបូង យើងអាចការពារប្រព័ន្ធសុខាភិបាល និងកាត់បន្ថយភាព ធ្ងន់ធ្ងរនៃជំងឺ និងការអាក់ខានសង្គម។ នៅក្នុង NDVP បានបញ្ចូលក្រុមងាយរងគ្រោះផ្សេង ទៀតផងដែរដូចជាមនុស្សចាស់ អ្នកមានជំងឺប្រចាំកាយ ដែលមានហានិភ័យឈឺដោយ សារជំងឺកូវីដ-១៩ នៅក្នុងឆ្នាំ ២០២១។

ចំនុចសំខាន់មួយទៀតនោះ ទោះបីរហូតដល់ពេលនេះ ប្រទេសកម្ពុជាមានករណីឆ្លងជំងឺកូវីដ-១៩ តិចតួចក៏ដោយ យើងបានរងផលប៉ះពាល់ធ្ងន់ធ្ងរផ្នែកសេដ្ឋកិច្ចសង្គម ដោយសារតែ ការឆ្លងរាតត្បាតជាសកលនេះ។ វ៉ាក់សាំងមិនគ្រាន់តែជួយសង្គ្រោះជីវិត និងធ្វើឱ្យប្រព័ន្ធសុខាភិបាល មានស្ថេរភាពប៉ុណ្ណោះទេ ប៉ុន្តែវាអាចជួយជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ច ដោយស្ដារនូវសង្គមកម្ពុជា-ការបើកឡើងវិញនៃសាលារៀន និងអាជីវកម្ម ជួយឱ្យមនុស្សបានធ្វើដំណើរ ទៅជួបជុំគ្រួសារ ជួយឱ្យកម្មករដែលមានប្រាក់ចំនូលទាបបានបន្តការរក ចំនូល។ល។

មិនមានប្រទេសណាមួយ រួមទាំងប្រទេសកម្ពុជា នឹងមានសុវត្ថិភាពពីការឆ្លងរាតត្បាតនេះទេ ដរាបណាគ្រប់ប្រទេសទាំងអស់ត្រូវបានការពារ។ ជំងឺកូវីដ-១៩ មិនអាចរាតត្បាតក្នុង ប្រទេសតែម្ដងនោះទេ។ ហានិភ័យគឺនៅតែមាន ដរាបណាករណីកូវីដ-១៩ នៅតែបន្តកើន ឡើងនៅលើសកលលោក ជាពិសេសនៅប្រទេសក្បែរខាងរបស់យើង។

វ៉ាក់សាំងគឺជា ឧបករណ៍ដ៏សំខាន់ រួមជាមួយនឹងវិធានការបង្ការផ្សេងៗ ដើម្បីបង្ការការឆ្លងជំងឺកូវីដ-១៩ និងសង្គ្រោះជីវិត។

២៤. ខ្ញុំខ្លួនឯងមិនប្រាកដសោះថាគួរចាក់វ៉ាក់សាំងឬទេ (ពីព្រោះខ្ញុំអត់មានធ្វើដំណើរទៅណាទេ មិនមានហានិភ័យនៃការឆ្លង ហើយមានធានារ៉ាប់រងសុខភាពថែមទៀត) ដូច្នេះតើខ្ញុំគួរចាក់ វ៉ាក់សាំងឬអត់?

អ្នកគួរតែចាក់វ៉ាក់សាំង ប្រសិនបើអ្នកស្ថិតក្នុងក្រុមអាទិភាព ឬ ក្រុមងាយរងគ្រោះ។ ប្រសិនបើអ្នកមិនស្ថិតក្នុងក្រុមនេះទេ អ្នកគួរអត់ធ្មត់រង់ចាំចាក់វ៉ាក់សាំង ដោយសារការផ្គត់ផ្គង់វ៉ាក់សាំងមានកំណត់ ហើយអាទិភាពគឺក្រុមដែលត្រូវការ ជាងគេ។

ប្រសិនបើអ្នកមិនប្រាកដថាអ្នកស្ថិតក្នុងក្រុមអាទិភាពឬអត់នោះ សូមពិភាក្សាជាមួយអ្នកផ្តល់ សេវា។

២៥. ខ្ញុំចាស់ហើយ និងមិនចេញទៅណាដែលជួបមនុស្សច្រើននោះទេ តើខ្ញុំគួរចាក់វ៉ាក់សាំងឬទេ?

អ្នកគួរតែចាក់វ៉ាក់សាំង ប្រសិនបើអ្នកស្ថិតក្នុងក្រុមអាទិភាព ឬ ក្រុមងាយរងគ្រោះ ទោះបីជា អ្នកមិនឃើញមានមនុស្សទៅចាក់ច្រើនក៏ដោយ។

ប្រសិនបើ អ្នកមិនស្ថិតក្នុងក្រុមនេះទេ អ្នកគួរអត់ធ្មត់រង់ចាំចាក់វ៉ាក់សាំង ដោយសារការ ផ្គត់ផ្គង់វ៉ាក់សាំងមានកំណត់ ហើយអាទិភាពគឺក្រុមដែលត្រូវការជាងគេ។

# ការជ្រើសរើស និងការចាក់វ៉ាក់សាំង

២៦. ហេតុអ្វីបានជាមានវ៉ាក់សាំងច្រើនប្រភេទម្ល៉េះ?

ពិភពលោកត្រូវការវ៉ាក់សាំងជាច្រើន ដើម្បីបំពេញតម្រូវការរបស់ពិភពលោក ដែលរងគ្រោះ ដោយការរាតត្បាតជាសកល។ តម្រូវការទាំងអស់នេះ គឺត្រូវការឱ្យមានក្រុមហ៊ុនជាច្រើនផលិតវ៉ាក់សាំងប្រភេទផ្សេងៗគ្នា។

ដំណើការនៃការអនុម័តគ្រប់វ៉ាក់សាំងកូវីដ-១៩ ថ្មីទាំងអស់ បានអនុវត្តតាមស្តង់ដារខ្ពស់សម្រាប់បទប្បញ្ញត្តិនៃវ៉ាក់សាំង។ ការសិក្សាស្រាវជ្រាវបានធ្វើឡើង មុនពេលវ៉ាក់សាំងដាក់ ឱ្យប្រើប្រាស់ គឺធ្វើឡើងដោយម៉ត់ចត់ដូចវ៉ាក់សាំងផ្សេងៗទៀតដូច្នោះដែរ។

[សូមមើលសំណួរទី១៥ សម្រាប់ព័ត៌មានលំអិតអំពីប្រភេទវ៉ាក់សាំង] ។

២៧. តើប្រទេសកម្ពុជាមានផែនការអ្វីខ្លះសម្រាប់ចាក់វ៉ាក់សាំងដល់ប្រជាជន?

ដោយមានការគាំទ្រពីអង្គការដៃគូ ក្រសួងសុខាភិបាលបានបង្កើតផែនការជាតិ ស្តីអំពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ និងបានចាប់ផ្តើមធ្វើផែនការគ្រប់ផ្នែកទាំងអស់សម្រាប់អនុវត្តនូវការចាក់វ៉ាក់សាំងថ្មីនេះ រួមមាន: បទប្បញ្ញត្តិ ភ័ស្តុភារ ការតាមដាននូវសុវត្ថិភាព ក្រុមអាទិភាពក្នុងការទទួលវ៉ាក់សាំង និងការប្រាស្រ័យទាក់ទង និងការចូលរួមពីសហគមន៍។

ផែនការជាតិ ស្តីអំពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ និងសេចក្តីណែនាំក្នុងការអនុវត្តត្រូវបានអនុម័ត ដោយក្រសួងសុខាភិបាល ហើយកំពុងរង់ចាំការអនុម័តចុងក្រោយ មុនពេលផ្សព្វផ្សាយជាសាធារណ។

ដោយសារតែវ៉ាក់សាំងមិនមានគ្រប់ដូសសម្រាប់ផ្តល់ឱ្យប្រជាជនគ្រប់រូប ក្នុងពេលតែមួយ គឺដូចទៅនឹងប្រទេសនានាលើពិភពលោកផងដែរ រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើផែនការដំណាក់កាលនៃការចាក់វ៉ាក់សាំង។ ក្រុមអាទិភាពនឹងត្រូវទទួលវ៉ាក់សាំងមុនគេ។

## ២៨. តើខ្ញុំធ្វើម៉េចទើបដឹងថា ត្រូវទៅចាក់វ៉ាក់សាំងនៅកន្លែងណា ពេលណា? ហើយតើវ៉ាក់សាំង ប្រឆាំងជំងឺកូវីដ-១៩ នឹងចាប់ផ្តើមចាក់នៅពេលណា?

រាជរដ្ឋាភិបាលកម្ពុជានឹងសម្ពោធប្រព័ន្ធចុះឈ្មោះចាក់វ៉ាក់សាំងតាមអនឡាញក្នុងពេលឆាប់ៗនេះ។ យើងនឹងផ្តល់ព័ត៌មានលំអិត និងសេចក្តីណែនាំក្នុងការចុះឈ្មោះ ទៅសាធារណជនក្នុងពេលឆាប់ៗនេះ។

ដោយសារលទ្ធកម្មនៃវ៉ាក់សាំងមានកំរិត ការចាក់វ៉ាក់សាំងនឹងធ្វើឡើងតាមដំណាក់កាល ហើយយើងផ្តល់អាទិភាពទៅអ្នកដែលចាំបាច់ត្រូវការមុន។

## ២៩. តើអ្វីខ្លះដែលត្រូវធ្វើដើម្បីការពារឆ្លងជំងឺកូវីដ-១៩ នៅពេលមកចាក់វ៉ាក់សាំង?

សុវត្ថិភាព របស់បុគ្គលិកសុខាភិបាល និងក្រុមគោលដៅ ដែលមកចាក់វ៉ាក់សាំងកូវីដ-១៩ គឺជារឿងសំខាន់ខ្លាំងណាស់។

នៅកន្លែងចាក់វ៉ាក់សាំង ក្រុមការងារចាក់វ៉ាក់សាំងទាំងអស់ និងបានទទួលម៉ាស់សម្រាប់ពាក់ ទឹកលាងដៃសម្លាប់មេរោគ ស្រោមដៃ ដើម្បីការពារពួកគាត់ និងអ្នកដែលមកចាក់វ៉ាក់សាំង។

មុនពេលចូលកន្លែងចាក់វ៉ាក់សាំង គ្រប់គ្នានឹងត្រូវវ៉ាស់កម្តៅ ពិនិត្យមើលពីការពាក់ ម៉ាស់ត្រឹមត្រូវ និងលាងដៃសម្អាតដៃ។

## ៣០. តើរាជរដ្ឋាភិបាលសម្រេចយកវ៉ាក់សាំងប្រភេទណាមួយមកចាក់ឲ្យប្រជាជន ដោយរបៀបណា ហើយមូលហេតុអ្វី?

ដោយមើលឃើញ ពីការបន្តគម្រាមគំហែងនៃជំងឺកូវីដ-១៩ មកលើប្រជាជនកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកវាជាអាទិភាពបន្ទាន់ ក្នុងការរកវ៉ាក់សាំងបង្ការអាយុជីវិតរបស់ប្រជាជនកម្ពុជា។ ដូចទៅនឹងប្រទេសដទៃទៀតដែរ រាជរដ្ឋាភិបាលកម្ពុជាសម្រេចចិត្តយក វ៉ាក់សាំងណាមួយ ដោយពឹងផ្អែកទៅលើប្រសិទ្ធភាព សុវត្ថិភាព ការផ្គត់ផ្គង់ និងតម្លៃ។

មកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសធានាឱ្យមានវ៉ាក់សាំងតាមរយៈប្រភពជាច្រើនដូចជា ជំនួយកូវ៉ាក ដែលជាការផ្គត់ផ្គង់តាមរយៈសហដឹកនាំដោយ Gavi CEPI និងអង្គការសុខភាពពិភពលោក ក្រោមភាពជាដៃគូជាមួយ UNICEF និងតាមរយៈកិច្ចព្រមព្រៀងផលិតទ្វេភាគី។ ដោយសារតែការផ្គត់ផ្គង់វ៉ាក់សាំងក្នុងពិភពលោកមានកំរិត រាជរដ្ឋាភិបាលបានទទួលយកគ្រប់មធ្យោបាយទាំងអស់នេះ ដើម្បី

បានវ៉ាក់សាំងដែលមានស្តង់ដារ ឱ្យលឿនតាមដែលអាចធ្វើបាន។

វ៉ាក់សាំងកូវីដ-១៩ ដំបូង នឹងមកដល់ស្រុកខ្មែរនៅថ្ងៃទី៧កុម្ភៈ។ វ៉ាក់សាំងនេះផលិតដោយក្រុមហ៊ុន ស៊ីណូហ្វាម ហើយជាជំនួយរបស់រដ្ឋាភិបាលចិន តាមការស្នើរសុំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ដោយយោងតាមទិដ្ឋភាពរួមនៃវ៉ាក់សាំងនេះ រួមទាំងមានបទពិសោធន៍ រាជរដ្ឋាភិបាលសម្រេចដាក់វ៉ាក់សាំងនេះ ប្រើក្នុងគ្រាអាសន្ន ហើយចាប់ផ្តើមចាក់ឱ្យក្រុម អាទិភាព។ រាជរដ្ឋាភិបាលបង្កើតនូវពិធីសារសុវត្ថិភាពវេជ្ជសាស្ត្រ ដើម្បីធ្វើឱ្យប្រាកដនូវ ការចាក់វ៉ាក់សាំងប្រកបដោយសុវត្ថិភាព។

មកដល់បច្ចុប្បន្ន មានប្រទេសជាច្រើនរួមមាន Bahrain ចិន អេស៊ីប អ៊ីរ៉ាក់ ជូដែន ប៉ាគីស្ថាន បេរ៉ូ សេប៊ៃ និងសហភាពអារ៉ាប់រួម បានដាក់វ៉ាក់សាំងនេះប្រើក្នុងគ្រាអាសន្ន។

មកត្រឹមថ្ងៃទី១១ កុម្ភៈនេះ វ៉ាក់សាំងស៊ីណូហ្វាម កំពុងត្រូវបានវាយតម្លៃដោយអង្គការសុខភាពពិភពលោក សម្រាប់ដាក់បញ្ចូលក្នុងបញ្ជីប្រើក្នុងគ្រាអាសន្ន (EUL) ដូចទៅនឹងវ៉ាក់សាំងជាច្រើនដទៃទៀត ដូចជាវ៉ាក់សាំងដែលផលិតដោយក្រុមហ៊ុន ម៉ូដែណា និង អាស្ត្រាសេនីកា របស់សាកលវិទ្យាល័យ Oxford ផងដែរ។ សេចក្តីសម្រេចរំពឹងថានឹងធ្វើឡើងនៅចុងខែមីនា។ មកដល់ថ្ងៃនេះ មានតែវ៉ាក់សាំងដែលផលិតឡើងដោយក្រុមហ៊ុន Pfizer មួយប៉ុណ្ណោះ ដែលបានទទួលការអនុម័តក្នុងបញ្ជីប្រើក្នុងគ្រាអាសន្ន (EUL) របស់អង្គការសុខភាពពិភពលោក។

### ៣១. តើដំណើរការនៃការអនុម័តយ៉ាងដូចម្តេចដែរ?

គ្រប់ដំណាក់កាលទាំងអស់នៃការផលិតវ៉ាក់សាំងកូវីដ-១៩ ត្រូវបានអនុវត្តដូចទៅ នឹងការផលិតវ៉ាក់សាំងដទៃផងដែរ។ វ៉ាក់សាំងគឺត្រូវការឆ្លងកាត់ជាច្រើនក្នុងការផលិត និងធ្វើតេស្តសាកល្បង ហើយជាទូទៅគឺមានការធ្វើតេស្តគ្លីនិកចំនួន៣លើក។គ្រប់ដំណាក់កាល ទាំងអស់គឺវាយតម្លៃទៅលើសុវត្ថិភាព។ ហើយការធ្វើតេស្តសាកល្បងលើកទី៣ គឺតែងតែធ្វើទៅលើមនុស្សជាច្រើននាក់ ហើយធម្មតាគឺមួយម៉ឺននាក់។

ប្រទេសកម្ពុជាអាជ្ញាធរបញ្ញត្តិរបស់ខ្លួនដែលស្ថិតនៅក្រោម ក្រសួងសុខាភិបាល។ ក្រសួងសុខាភិបាលនឹងចេញសេចក្តីប្រកាសអនុញ្ញាតិឱ្យប្រើប្រាស់វ៉ាក់សាំងក្នុងគ្រាអាសន្នបន្ទាប់ពីបានពិនិត្យលើទិន្នន័យដែលមានពីអាជ្ញាធរបទប្បញ្ញត្តិ នៃប្រទេសផ្សេងទៅលើសុវត្ថិភាព និងប្រសិទ្ធភាពរបស់វ៉ាក់សាំងនោះ ឬ បន្ទាប់ពីវ៉ាក់សាំងនោះបានដាក់បញ្ចូលទៅក្នុងបញ្ជី ប្រើប្រាស់ក្នុងគ្រាអាសន្នរបស់អង្គការសុខភាពពិភពលោក (EUL)។

នៅពេលដែលវ៉ាក់សាំងដាក់ ឱ្យប្រើប្រាស់នោះនឹងមានការតាមដាន ដើម្បីឱ្យប្រាកដថា មានសុវត្ថិភាពដល់អ្នកចាក់វ៉ាក់សាំង។

### ៣២. តើអង្គការសហប្រជាជាតិមានចូលរួមក្នុងការធ្វើផែនការនៃការចាក់វ៉ាក់សាំងនៅក្នុងប្រទេស កម្ពុជាដែរឬទេ?

អង្គការសុខភាពពិភពលោក និងយូនីសេហ្វ គឺជាដៃគូអង្គការសហប្រជាជាតិ របស់ប្រទេសកម្ពុជាយូរអង្វែងមកហើយ ក្នុងកម្មវិធីផ្តល់ថ្នាំបង្ការ។ អង្គការសហប្រជាជាតិពីរនេះ គឺជាដៃគូដ៏សំខាន់ក្នុងការគាំទ្រការត្រៀមរបស់ប្រទេស ក្នុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩។ គេផ្តល់ជំនួយបច្ចេកទេស និងគាំទ្រគ្រប់វិស័យសំខាន់ៗរួមមាន ការបង្កើតនូវ យុទ្ធសាស្រ្ត ផែនការ ប្រព័ន្ធត្រជាក់ ការពង្រឹងសមត្ថភាព ការប្រាស្រ័យទាក់ទង សុវត្ថិភាព និងការឃ្លាំមើល និងការតាមដាន។ ការសម្រេចចុងក្រោយ គឺអាស្រ័យលើរាជរដ្ឋាភិបាលកម្ពុជា។

ភ្នាក់ងារអង្គការសហប្រជាជាតិ មិនពាក់ព័ន្ធផ្ទាល់នៅក្នុងលទ្ធកម្មវ៉ាក់សាំង តាមរយៈកិច្ចព្រមព្រៀងសហការទ្វេភាគីនោះទេ។ ប៉ុន្តែយូនីសេហ្វ នឹងគាំទ្រលទ្ធកម្មវ៉ាក់សាំងតាមរយៈយន្តការកូវ៉ាក់សកល ដោយសារតែយូនីសេហ្វត្រូវបានចាត់តាំងជាភ្នាក់ងារទទួលបន្ទុកផ្នែកលទ្ធកម្មនេះទូទាំងពិភពលោក។ យន្តការកូវ៉ាក់នឹងផ្តល់ឱ្យប្រទេសជាសមាជិកនូវវ៉ាក់សាំងដែលបានការអនុម័តពី WHO EUL ឬ ពីអាជ្ញាធរនិយ័តកម្មសហគមន៍អឺរ៉ុប (SRA)។

## ៣៣. ហេតុអ្វីបានជាខ្ញុំត្រូវចាក់វ៉ាក់សាំងស៊ីណូហ្វាម បើខ្ញុំបានឮមកថា វាជាវ៉ាក់សាំង នយោបាយ?

គ្រប់រដ្ឋាភិបាលនៃប្រទេសនៅលើពិភពលោកជួបប្រទះនូវការប្រជែងយកវ៉ាក់សាំង សម្រាប់ចាក់ឱ្យប្រជាជនរបស់ខ្លួនឱ្យបានច្រើន ហើយឱ្យបានលឿនតាមដែលអាចធ្វើបាន។ រដ្ឋាភិបាលប្រទេសនីមួយៗមានសិទ្ធិ ក្នុងការសម្រេចចិត្តជ្រើសរើសវិធីសាស្រ្តល្អ បំផុតសម្រាប់ការចាក់វ៉ាក់សាំង ហើយតែងតែផ្តល់អាទិភាពទៅលើសុវត្ថិភាពរបស់ប្រជាជនជានិច្ច រួមទាំងអ្នកដែលមានភាពងាយរងគ្រោះទៅនឹងជំងឺ និងពិចារណាលើការស្តារឡើងវិញ នូវសេដ្ឋកិច្ចសង្គម។ ដូចទៅនឹងប្រទេសដទៃដែរ រាជរដ្ឋាភិបាលកម្ពុជាសម្រេចយកវ៉ាក់សាំងណាមួយដោយអាស្រ័យទៅលើ ប្រសិទ្ធភាព សុវត្ថិភាព គុណភាព ការផ្គត់ផ្គង់ និងតម្លៃរបស់វ៉ាក់សាំង។

យោងតាមទិដ្ឋភាពរួមរបស់វ៉ាក់សាំង និងបទពិសោធន៍ពីប្រទេសផ្សេង រួមមាន ប្រទេសចិន អេស៊ីប ចូដែន និងប្រទេសផ្សេងទៀត រដ្ឋាភិបាលបានអនុញ្ញាតិឱ្យប្រើប្រាស់ជាផ្លូវការនូវវ៉ាក់សាំងស៊ីណូហ្វាម ហើយចាប់ផ្តើមចាក់ឱ្យក្រុមអាទិភាព។ ក្នុងដំណាក់កាលដំបូង វ៉ាក់សាំងនឹងប្រើ សម្រាប់ការពារបុគ្គលិកសុខាភិបាល មន្ត្រីរាជការជួរមុខ ដែលការពារប្រព័ន្ធ សុខាភិបាល និងសង្គម។

រាជរដ្ឋាភិបាលកម្ពុជា ក៏មានផែនការទទួលយកវ៉ាក់សាំងផ្សេងទៀត ផងដែរ តាមរយៈកូវ៉ាក ការផ្តល់ជំនួយ និងកិច្ចព្រមព្រៀងទ្វេភាគី ដើម្បីសម្រេចទិសដៅជាតិក្នុងការចាក់វ៉ាក់សាំង ឱ្យបាន១០លាននាក់។

## ៣៤. តើវ៉ាក់សាំងមួយណាល្អជាងគេ វ៉ាក់សាំងអាមេរិក អង់គ្លេស ឬ ចិន?

គ្រប់វ៉ាក់សាំងទាំងអស់គឺសុទ្ធតែឆ្លងកាត់ដំណាក់កាលដូចគ្នាក្នុងការផលិត មិនថាវាផលិតដោយក្រុមហ៊ុនណានោះទេ គឺត្រូវតែ

ឆ្លងកាត់ការធ្វើតេស្តសាកល្បងយ៉ាងទូលំទូលាយ និងម៉ត់ចត់ មុនពេលដាក់ឱ្យប្រើក្នុងប្រទេសណាមួយ។ គ្រប់វ៉ាក់សាំងទាំងអស់សុទ្ធតែឆ្លងកាត់ដំណាក់កាលជាច្រើននៃការផលិត និងធ្វើតេស្ត។ ជាទូទៅគឺមានការធ្វើតេស្តគ្លីនិកចំនួន ៣ លើក។ គ្រប់ដំណាក់កាលទាំងអស់ គឺវាយតម្លៃទៅលើ សុវត្ថិភាព។ ហើយការធ្វើតេស្តសាក ល្បងលើកទី៣ គឺតែងតែធ្វើទៅលើ មនុស្សជាច្រើននាក់ ហើយធម្មតាគឺមួយម៉ឺននាក់។

ដោយមើលឃើញពីការបន្តគម្រាមគំហែងនៃជំងឺកូវីដ-១៩ មកលើប្រជាជនកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកវាជាអាទិភាពបន្ទាន់ក្នុងការរកវ៉ាក់សាំងបង្ការអាយុជីវិតរបស់ប្រជាជនកម្ពុជា។ ដូចទៅនឹងប្រទេសដទៃទៀតដែរ រាជរដ្ឋាភិបាលកម្ពុជាសម្រេចចិត្តយកវ៉ាក់សាំងណាមួយ ដោយពឹងផ្អែកទៅលើប្រសិទ្ធភាព សុវត្ថិភាព ការផ្គត់ផ្គង់ និងតម្លៃ។

ដោយសារលទ្ធកម្មរបស់វ៉ាក់សាំងសម្រាប់ពិភពលោកមានកំរិត រាជរដ្ឋាភិបាលកម្ពុជាបានទទួលយកនូវវ៉ាក់សាំងពីច្រើនប្រភព៖ តាមរយៈកូវ៉ាក់ ការផ្តល់ជំនួយ និងកិច្ចព្រមព្រៀងទ្វេភាគី ដើម្បីទទួលបានវ៉ាក់សាំងដែលមានស្តង់ដាបញ្ញាតិ ឱ្យលឿនតាមដែលអាចធ្វើទៅបាន។

នៅពេលដែលវ៉ាក់សាំងដាក់ឱ្យប្រើប្រាស់ វ៉ាក់សាំងនឹងបន្តទទួលការត្រួតពិនិត្យ ដើម្បីឱ្យប្រាកដថាវាមានសុវត្ថិភាពពេញលេញសម្រាប់អ្នកដែលបានចាក់វា។

## ៣៥. តើវ៉ាក់សាំងទាំងនេះមានតម្លៃប៉ុន្មាន?

វ៉ាក់សាំងមានតម្លៃខុសៗគ្នា។ វ៉ាក់សាំងខ្លះគឺជាអំណោយមកប្រទេសកម្ពុជាដោយមិនគិតថវិកា ខ្លះទៀតដូចជាតាមរយៈកូវ៉ាក គឺជាការឧបត្ថម្ភបន្ថែម។

## ៣៦. តើខ្ញុំអាចធ្វើអ្វីខ្លះបានដើម្បីគាំទ្រដល់យុទ្ធនាការចាក់វ៉ាក់សាំង?

ប្រសិនបើអ្នកមិនស្ថិត ក្នុងក្រុមអាទិភាព សូមរង់ចាំដោយការអត់ធ្មត់ ដោយសារលទ្ធកម្មវ៉ាក់សាំងមានកំរិត ហើយវាត្រូវផ្តល់ឱ្យអ្នកដែលត្រូវការវាជាចាំបាច់មុនសិន។ ប្រសិនបើអ្នកស្ថិតក្នុងក្រុមអាទិភាព អ្នកត្រូវបានលើកទឹកចិត្តឱ្យទៅចាក់វ៉ាក់សាំង។ វ៉ាក់ សាំងគឺមានសុវត្ថិភាព និងមានប្រសិទ្ធភាព។

សូមបន្តអនុវត្តវិធានការបង្ការខ្លួនអ្នក និងអ្នកដទៃ ដូចជា លាងដៃ ពាក់ម៉ាស់ និងរក្សាចម្ងាយពីអ្នកដទៃ ទោះបីជាអ្នកបានចាក់វ៉ាក់សាំងរួចហើយក៏ដោយ។

ជួយជនងាយរងគ្រោះដែលអ្នកស្គាល់ ដូចជាមនុស្សចាស់ ចុះឈ្មោះសម្រាប់ចាក់វ៉ាក់សាំង និងនាំគាត់ទៅកន្លែងចាក់វ៉ាក់សាំង។

មុនពេលចែកចាយព័ត៌មាន ឬ ប្រធានបទអំពីវ៉ាក់សាំង ឬ បញ្ហាសុខភាពផ្សេងៗ សូមពិនិត្យមើលប្រភពជឿជាក់បាន ដូចជាក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក និងយូនីសេហ្វ។ ប្រសិនបើអ្នកជឿថាវាជាព័ត៌មានមិនពិត សូមរាយការណ៍។ ការពារខ្លួនអ្នក និងអ្នកដទៃពីព័ត៌មានមិនពិត។

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅលេខ 115 ដោយឥតគិតថ្លៃ!